ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧.សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសំរបសំរួល និងដោះស្រាយវិវាទ នៅតំបន់វិនិយោគរបស់ក្រុមហ៊ុន តំបន់សេដ្ឋកិច្ចពិសេសគីរីសាគរ កោះកុង ក្នុងភូមិសាស្ត្រ ឃុំព្រែកខ្សាច់ និងឃុំភ្ញីមាស ស្រុកគីរីសាគរ និងឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកត/១២៩១/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ/បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១២៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេសគីរីសាគរ កោះកុង
- យោងតាមភាពចាំបាច់របស់រាជរដ្ឋាភិបាល

www.pheakdeylaw.com

# សម្រេច

**ប្រការ១:** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីសំរបសំរួល និងដោះស្រាយបញ្ហាវិវាទ ដែលកើតមានក្នុងតំបន់វិនិយោគរបស់ក្រុមហ៊ុន **តំបន់សេដ្ឋកិច្ចពិសេសគីរីសាគរ កោះកុង** ក្នុងភូមិសាស្រ្តឃុំព្រែកខ្សាច់ និងឃុំភ្ញីមាស ស្រុកគីរីសាគរ និងឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉េត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | ប្រធាន |
| ២-ឯកឧត្តម **សុខ ចិន្តា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | អនុប្រធាន |
| ៣-ឯកឧត្តម **ឡោក់ ចាម** | រដ្ឋលេខាធិការក្រសួងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៤-ឯកឧត្តម **ចាយ សាំងយុន** | រដ្ឋលេខាធិការក្រសួងការពារជាតិ និងជាអគ្គលេខាធិការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | សមាជិក |
| ៥-ឯកឧត្តម **នូ សុវត្ថិ** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦-ឯកឧត្តម **ម៉ុល លឹម** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៧-ឯកឧត្តម **ហ៊ុន ឌូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨-ឯកឧត្តម **គិត សេង** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩-ឯកឧត្តម **ហ៊ាង សាហ៊ុំ** | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០-ឯកឧត្តម **យុន្ទ ភុមរ** | អភិបាលខេត្តកោះកុង | សមាជិក |
| ១១-ឧត្តមសេនីយ៍ឯក **ខឿ ពិសែន** មេបញ្ជាការរង និងជានាយសេនាធិការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |
| ១២- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន | | លេខាធិការ |

**ប្រការ២:** គណៈកម្មការអន្តរក្រសួង មានតួនាទី ភារកិច្ច និងបេសកកម្ម សំរាប់ករណីវិវាទ ដែលកើតមានក្នុងតំបន់វិនិយោគរបស់ក្រុមហ៊ុន **តំបន់សេដ្ឋកិច្ចពិសេសគីរីសាគរ កោះកុង** ក្នុងភូមិសាស្រ្តឃុំព្រែកខ្សាច់ និងឃុំភ្ញីមាស ស្រុកគីរីសាគរ និងឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង ដូចតទៅ :

១- ពិនិត្យ ធ្វើការសំរបសំរួល ផ្តល់យោបល់ និងដោះស្រាយវិវាទ ពាក់ព័ន្ធនឹងទីតាំងវិនិយោគនេះ សំដៅធ្វើយ៉ាងណា បង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុន **តំបន់សេដ្ឋកិច្ចពិសេសគីរីសាគរ កោះកុង** អាចដំណើរការអភិវឌ្ឍន៍បានដោយរលូន ។

២- ចូលរួមពិភាក្សា ផ្តល់យោបល់ លើការងារអភិរក្ស និងអភិវឌ្ឍន៍ក្នុងតំបន់វិនិយោគ ។

៣- លើកវិធានការទប់ស្កាត់ និងដោះស្រាយជាបន្ទាន់ នូវរាល់សកម្មភាពអនាធិបតេយ្យដែលកើតមានឡើងក្នុងតំបន់អភិវឌ្ឍន៍របស់ក្រុមហ៊ុន ។

៤- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលនូវលទ្ធផលការងាររបស់ខ្លួន ។

**ប្រការ៣:** សមាជិកគណៈកម្មការអន្តរក្រសួង ដែលតំណាងអោយក្រសួង-ស្ថាប័ន ខេត្តពាក់ព័ន្ធ ត្រូវចូលរួមទទួលខុសត្រូវ ក្នុងក្របខណ្ឌសមត្ថកិច្ច ភារកិច្ច ដែលបានចែងក្នុងប្រការ២ ខាងលើ និងត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង ។

**ប្រការ៤:** គណៈកម្មការអន្តរក្រសួង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន និងមានលេខាធិការដ្ឋានមួយ ដែលមានទីតាំងនៅក្រសួងបរិស្ថាន ។

**ប្រការ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុក អនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៥ "ដើម្បីជូនជ្រាប និងអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com